# សំនួរដែលគេសួរជារឿយៗ របាយការណ៍សិស្សម្នាក់ៗ

NAPLAN

2021

NAPLAN គឺជាការធ្វើតេស្តថ្នាក់ជាតិដើម្បីវាយតម្លៃចំណេះដឹងក្នុងវិស័យអាននិងសរសេរ និងវិស័យគិតលេខ សម្រាប់សិស្សឆ្នាំទី៣, ៥, ៧ និង ៩ ដែលធ្វើឡើងនៅខែឧសភារៀងរាល់ឆ្នាំ។ ជំនាញក្នុងការអាននិងសរសេរហើយនិងក្នុងការគិតលេខ ជាមូលដ្ឋានយ៉ាងសំខាន់សម្រាប់ការសិក្សាគ្រប់វិស័យ។ NAPLAN គឺជាការវាយតម្លៃថ្នាក់ជាតិតែមួយគត់ដែលកុមារអូស្ត្រាលីគ្រប់រូបអាចធ្វើ។ សំនួរទាំងពួងសួរអំពីចំណេះដឹងដែលផ្សារភ្ជាប់ទៅនិងកម្មវិធីសិក្សាអូស្ត្រាលី ៖ ភាសាអង់គ្លេស និងគណិតវិទ្យា

លទ្ធផលពី NAPLAN អនុញ្ញាតិឲ្យមាតាបិតា/អ្នកថែទាំ និងគ្រូបង្ហាត់ ឃើញថាសិស្សមានការលូតលាស់យ៉ាងណាក្នុងវិស័យអាននិងសរសេរហើយនិងវិស័យគិតលេខពីមួយឆ្នាំទៅមួយឆ្នាំ – សម្រាប់សិស្សនិមួយៗ ក្នុងរង្វង់សាលារបស់ខ្លួនហើយនិងប្រៀបធៀបទៅនិងស្តង់ដាជាតិ។

ការធ្វើតេស្ត NAPLAN ជាផ្នែកមួយនៃកម្មវិធីវាយតម្លៃនិងរាយការណ៍ តែមិនជំនួសការវាយតម្លៃយ៉ាងពេញលេញនិងជាប្រចាំលើសមត្ថភាពរបស់សិស្សនិមួយៗ ដែលធ្វើឡើងដោយគ្រូឡើយ។ គ្រូរបស់កូនអ្នក មើលដឹងច្បាស់ជាងគេការលូតលាស់របស់កូនអ្នកក្នុងការសិក្សារបស់គេ។ ជួបជាមួយនិងរបាយការណ៍វាយតម្លៃដទៃទៀតរបស់សាលា គេអាចប្រើរបាយការណ៍របស់ NAPLAN ដើម្បីពិភាក្សាលើចំណុចខ្លាំងនិងចំណុចដែលត្រូវកែលំអរបស់កូនអ្នក ជាមួយនិងគ្រូរបស់គេ។

## តើនៅពេលណាខ្ញុំនឹងទទួលបានរបាយការណ៍ NAPLAN របស់កូនខ្ញុំ ហើយតើវានឹងប្រាប់ខ្ញុំឲ្យដឹងអ្វីខ្លះ ?

ប្រសិនបើអ្នកជាមាតាឬបិតា/អ្នកថែទាំ របស់សិស្សដែលបានធ្វើតេស្ត NAPLAN ក្នុងខែឧសភានាឆ្នាំនេះ សាលារបស់កូនអ្នកនឹងផ្តល់ជូនអ្នកនូវរបាយការណ៍ផ្ទាល់ខ្លួនអំពីលទ្ធផលរបស់កូនអ្នក។

អ្នកអាចរំពឹងទុកថា អ្នកត្រូវទទួលរបាយការណ៍ NAPLAN របស់កូនអ្នកចាប់ពីខែសីហាទៅ នៅពេលដែលអាជ្ញាធររដ្ឋឬដែនដី (www.nap.edu.au/taa) បានប្រគល់របាយការណ៍ផ្ទាល់ខ្លួនរបស់សិស្សានុសិស្សទៅសាលារួច។

អ្នកនឹងឃើញគំនូសសញ្ញារង្វាស់(ឬកប៉ាល់រ៉ុកកែត) ចំនួនប្រាំដែលបង្ហាញលទ្ធផល NAPLAN របស់កូនអ្នកសម្រាប់ការអាន សរសេរ ប្រកបពាក្យ វេយ្យាករណ៍&ការប្រើវណ្ណយុត្ត ហើយនិងការគិតលេខ។

លទ្ធផលនៃការវាយតម្លៃលើការអាននិងសរសេរ ហើយនិងការគិតលេខសម្រាប់ឆ្នាំទី៣, ៥, ៧ និង ៩ នឹងត្រូវបានរាយការណ៍ដែលមានរង្វាស់ជាបន្ទះៗចាប់ពីបន្ទះទី១ដល់បន្ទះទី១០។ រង្វាស់នេះតំណាងឲ្យកំរិតដែលកើនកាន់តែខ្ពស់ទៅរបស់ចំណេះ ការយល់ និងជំនាញដែលសមីខ្លួនបានបង្ហាញឲ្យឃើញក្នុងពេលវាយតម្លៃ។

## តើការផ្តល់ NAPLAN នៅសាលាទាំងឡាយធ្វើឡើងដោយវិធីណា ?

NAPLAN កំពុងតែប្តូរទៅធ្វើតាមអនឡាញវិញ ដោយមានបំណងឲ្យគ្រប់សាលាទាំងអស់ប្តូរពីការធ្វើតេស្តដោយប្រើក្រដាស ទៅជាអនឡាញឲ្យអស់ត្រឹមឆ្នាំ២០២២។

នេះគឺមានន័យថា ក្នុងខែឧសភាឆ្នាំ២០២១ សិស្សខ្លះធ្វើតេស្តដោយប្រើក្រដាស ហើយខ្លះទៀតធ្វើតាមអនឡាញ។

NAPLAN តាមអនឡាញ ធ្វើឲ្យមានការវាយតម្លៃបានល្អជាង លទ្ធផលសុក្រិតជាង ហើយធ្វើឲ្យសិស្សមានសកម្មភាពច្រើនជាង។

## តើខ្ញុំមើលរបាយការណ៍របៀបម៉េច ?

នៅខាងក្រោមរូបកប៉ាល់រ៉ុកកែតនិមួយៗ មានការរៀបរាប់ថាកូនរបស់អ្នកបានធ្វើតេស្តតាមអនឡាញឬតាមក្រដាស។ គ្រប់សិស្សឆ្នាំទី៣ទាំងអស់ធ្វើតេស្តតាមការសរសេរលើក្រដាស

ទោះបីសិស្សបានធ្វើតេស្តតាមអនឡាញក៏ដោយឬតាម ក្រដាសក៏ដោយ ៖

- សិស្សនឹងត្រូវបានវាយតម្លៃលើជំនាញនៃការអាននិងសរសេរ និងនៃការគិតលេខដូចគ្នាដែលគ្រូបានបង្រៀនតាមកម្មវិធីសិក្សា។
- លទ្ធផលរបស់សិស្សនឹងបន្តមានការវាស់វែងដោយផ្អែកលើខ្នាតនៃការវាយតម្លៃរបស់ NAPLAN ដូចគ្នា មានន័យថាលទ្ធផលរបស់របៀបទាំងពីរ គឺប្រហាក់ប្រហែលគ្នា។

NAPLAN ជាឧបករណ៍មានតម្លៃមួយដែលអាចឲ្យគេឃើញជ្រៅនូវការធ្វើបានរបស់សិស្សពីមួយឆ្នាំទៅមួយឆ្នាំ ប៉ុន្តែគេត្រូវបកស្រាយលទ្ធផលរបស់សិស្សម្នាក់ៗដោយប្រុងប្រយ័ត្ន ព្រោះវាបញ្ចាំងការធ្វើបានរបស់សិស្សនាថ្ងៃធ្វើតេស្ត។

របាយការណ៍របស់សិស្សមានបង្ហាញតែបន្ទះប្រាំមួយដែលមានន័យជាងគេ សម្រាប់ថ្នាក់និមួយៗ។ របាយការណ៍ថ្នាក់ឆ្នាំទី៣បង្ហាញបន្ទះទី១–៦ ថ្នាក់ឆ្នាំទី៥ បង្ហាញបន្ទះទី៣–៨ ថ្នាក់ឆ្នាំទី៧បង្ហាញបន្ទះទី៤–៩ ហើយថ្នាក់ឆ្នាំទី៩បង្ហាញបន្ទះទី៥–១០។ រូបឌីយ៉ាក្រាមនៅក្នុងរបាយកាណ៍របស់សិស្សបង្ហាញទំហំរបស់៦០ភាគរយនៃសិស្សកណ្តាល លទ្ធផលមធ្យមភាគទូទាំងប្រទេស ហើយនិងស្តង់ដាអប្បបរមាសម្រាប់ទូទាំងប្រទេស សម្រាប់ថ្នាក់និមួយៗ។ របាយការណ៍ក្នុងរដ្ឋនិងដែនដីខ្លះ ក៏មានបង្ហាញមធ្យមភាគប្រចាំសាលានិង/ឬរដ្ឋផងដែរ។ របាយការណ៍នោះក៏ធ្វើការសង្ខេបអំពីជំនាញដែលសិស្សតែងតែបង្ហាញឲ្យឃើញនៅក្នុងការវាយតម្លៃក្នុងបន្ទះនិមួយៗ។

## តើ NAPLAN ជួយកូនខ្ញុំដោយវិធីណា ?

NAPLAN ផ្តល់ឱកាសឲ្យសិស្សានុសិស្សបង្ហាញនូវអ្វីដែលពួកគេបានរៀនក្នុងវិស័យអាននិងសរសេរ ហើយនិងវិស័យគិតលេខ។ លទ្ធផលរបស់សិស្សម្នាក់ៗបង្ហាញឲ្យមាតាបិតា/អ្នកថែទាំឃើញថាតើកូនរបស់គាត់ធ្វើបានល្អប៉ុណ្ណាក្នុងការធ្វើតេស្តអាន សរសេរ ប្រកបពាក្យ វេយ្យាករណ៍&ការប្រើវណ្ណយុត្ត ហើយនិងការគិតលេខ។

លទ្ធផលធ្វើបានរបស់កូនអ្នកត្រូវបានប្រៀបធៀបជាមួយលទ្ធផលធ្វើបានរបស់សិស្សដទៃទាំងអស់ គឺមិនមែនតែជាមួយលទ្ធផលធ្វើបានរបស់សិស្សរួមថ្នាក់ទេ។ លទ្ធផល NAPLAN អាចជួយមាតាបិតានិងសិស្សក្នុងការពិភាក្សាជាមួយគ្រូ អំពីការលូតលាស់របស់សិស្សម្នាក់ៗ។ ដោយសារ NAPLAN តាមដានការលូតលាស់របស់កូនអ្នកក្នុងអំឡុងពេលឆ្លងកាត់ឆ្នាំទី៣, ៥, ៧, និង៩ វាក៏ផ្តល់ព័ត៌មានមិនលំអៀងអំពីការរីកចម្រើននៃចំណេះរបស់សិស្សក្នុងវិស័យអាននិងសរសេរ ហើយនិងវិស័យគិតលេខ។

## តើលទ្ធផលនោះនឹងមានឥទ្ធិពលអ្វីដល់អនាគតរបស់កូនខ្ញុំ ?

លទ្ធផល NAPLAN ផ្តល់ព័ត៌មានសំខាន់អំពីជំនាញក្នុងការអាននិងសរសេរ និងការគិតលេខដែលកូនអ្នករៀនតាមរយៈកម្មវិធីសិក្សាធម្មតានៅសាលា។ លទ្ធផលទាំងនេះផ្គួបជាមួយនិងការវាយតម្លៃដទៃទៀតដែលកូនរបស់អ្នកបានធ្វើនៅសាលា នឹងធ្វើឲ្យវាមានភាពពេញលេញ។ លទ្ធផលទាំងនេះធ្វើឲ្យអ្នកនិងគ្រូរបស់កូនអ្នកយល់អំពីសមិទ្ធិផលនិងការលូតលាស់របស់កូនអ្នកនាសម័យពេលវាយតម្លៃ។ ព័ត៌មាននេះអាចប្រើសម្រាប់ជួយឲ្យកូនរបស់អ្នកធ្វើបានខ្ពស់បំផុតដែលប្រើសមត្ថភាពគ្រប់ទាំងអស់របស់ខ្លួន។

សាលាខ្លះអាចសួររករបាយការណ៍ NAPLAN ថែមទៅលើរបាយការណ៍របស់សាលា ដែលជាផ្នែកមួយនៃបែបបទទទួលយកសិស្សចូលរបស់សាលានោះ។ ការវាយតម្លៃរបស់ NAPLAN មិនមែនរចនាឡើងដើម្បីធ្វើជាតេស្តសម្រាប់ទទួលសិស្សចូលឡើយ។ ទោះជាយ៉ាងណា លទ្ធផលអាចមានប្រយោជន៍សម្រាប់ឲ្យសាលាថ្មីដឹងថាតើសិស្សត្រូវការអ្វីខ្លះ។ ប្រសិនបើអ្នកមានការបារម្ភអ្វី អាជ្ញាធរ ACARA លើកទឹកចិត្តឲ្យអ្នកទៅពិគ្រោះជាមួយសាលាអំពីការបារម្ភទាំងនោះ។

## តើ NAPLAN ជួយសាលាខ្ញុំដោយរបៀបណា ?

NAPLAN ជាការវាយតម្លៃថ្នាក់ជាតិតែមួយគត់ដែលកុមារអូស្ត្រាលីធ្វើ។ NAPLAN ជួយ ៖

- គ្រូក្នុងការសំគាល់ដឹងកាន់តែច្បាស់ នូវសិស្សដែលត្រូវការកិច្ចការពិបាកធ្វើជាងមុន ឬដែលត្រូវការជំនួយបន្ថែម។
- សាលាក្នុងការសំគាល់ដឹងចំណុចខ្លាំងនិងចំណុចដែលត្រូវការជំនួយ របស់កម្មវិធីបង្រៀន
- សាលាក្នុងការកំណត់គោលដៅក្នុងវិស័យអាននិងសរសេរ និងក្នុងវិស័យគិតលេខ។
- ប្រព័ន្ធសាលាក្នុងការពិនិត្យឡើងវិញនូវកម្មវិធីនិងជំនួយដែលផ្តល់ឲ្យទៅសាលាទាំងពួង។
- សហគមន៍ក្នុងការមើលនៅក្នុងគេហទំព័រ *My School* នូវលទ្ធផលមធ្យមភាគរបស់សាលា។

NAPLAN ក៏ជួយបន្ថែមដែលធ្វើឲ្យការវាយតម្លៃឯទៀតរបស់សាលាមានភាពពេញលេញ និងផ្តល់ ទិន្នន័យដែលអាចប្រៀបធៀបគ្នាបានក្នុងទូទាំងប្រទេសដើម្បីជួយរដ្ឋាភិបាលទាំងឡាយក្នុងការវាយតម្លៃឲ្យដឹងថាកម្មវិធីសិក្សាប្រព្រឹត្តទៅបានយ៉ាងណា ហើយនិងតើសិស្សានុសិស្សធ្វើបានដល់ស្តង់ដាដែលសំខាន់ក្នុងវិស័យអាននិងសរសេរ និងវិស័យគិតលេខឬអត់។

## តើអ្នកណាទៀតនឹងឃើញលទ្ធផល ?

ក្នុងឆ្នាំនិមួយៗ អាជ្ញាធររដ្ឋបាលទទួលបន្ទុកកិច្ចការធ្វើតេស្ត ផ្តល់ទៅសាលាទាំងពួងនូវលទ្ធផលសម្រាប់សិស្សទាំងអស់ដែលធ្វើតេស្ត NAPLAN ។ សាលាទាំងឡាយត្រូវបានលើកទឹកចិត្តឲ្យប្រើលទ្ធផលទាំងនោះដើម្បីផ្តល់ដំណឹងអំពីផែនការរបស់ខ្លួនក្នុងការធ្វើឲ្យសាលាទាំងមូលបានកាន់តែប្រសើរ។ របាយកាណ៍របស់សិស្សម្នាក់ៗ មានការរក្សាភាពសំងាត់។ គ្មានអ្នកណាក្រៅពីអាជ្ញាធររដ្ឋបាលទទួលបន្ទុកកិច្ចការធ្វើតេស្តប្រចាំមូលដ្ឋានរបស់អ្នក ឬក៏សាលារបស់អ្នកនឹងឃើញរបាយការណ៍របស់កូនអ្នកឡើយ។

លទ្ធផលមធ្យមភាគរបស់សាលាត្រូវបានរាយការណ៍ជាសាធារណ: នៅក្នុង *My School* (www.myschool.edu.au). ។ គេហទំព័រនេះមានធ្វើបច្ចុប្បន្នភាពដោយបញ្ចូលលទ្ធផលពីឆ្នាំកន្លងទៅ នៅត្រីមាសទីមួយជារៀងរាល់ឆ្នាំ។ *My School* អនុញ្ញាតិឲ្យសហគមន៍មើលផ្នែកនានានៃប្រវត្តនិងព័ត៌មានទាំងឡាយរបស់សាលានិមួយៗ ព្រមទាំងដើម្បីធ្វើការប្រៀបធៀបជាមួយសាលាទាំងឡាយដែលមានចំនួនសិស្សស្របើៗគ្នា។ លទ្ធផលផ្ទាល់ខ្លួនរបស់កូនអ្នក មិនមានដាក់នៅក្នុង *My School* ទេ។

## ចុះបើលទ្ធផលមិនដូចអ្វីដែលកូនខ្ញុំនិងខ្ញុំរំពឹងទុក?

តេស្ត NAPLAN ធ្វើការវាយតម្លៃការលូតលាស់ក្នុងវិស័យអាននិងសរសេរ និងវិស័យគិតលេខ។ សិស្សត្រូវបានគេឲ្យដឹងថាលទ្ធផលរបស់គេស្ថិតនៅម្តុំណាក្នុងរង្វាស់ពិន្ទុនៃការវាយតម្លៃសម្រាប់តេស្តនិមួយៗ។ ទោះបីលទ្ធផល NAPLAN គេអាចធ្វើការប្រៀបធៀបរវាងសិស្សទាំងអស់ក្នុងទូទាំងប្រទេស ហើយនិងរវាងពេលមួយនិងពេលមួយទៀតបាន អ្វីដែលកើតឡើងចំពោះសិស្សនៅថ្ងៃធ្វើតេស្តនោះអាចមានការប៉ះពាល់ដល់ការធ្វើបានរបស់សិស្សនោះ។

បើអ្នកមានសំនួរ ឬការបារម្ភអ្វីអំពីលទ្ធផល NAPLAN របស់កូនអ្នក អ្នកគួរពិគ្រោះជាមួយគ្រូរបស់កូនអ្នក ដែលគាត់មានការយល់ដឹងច្បាស់ជាងគេអំពីការលូតលាស់របស់កូនអ្នក។

ដើម្បីស្វែងរកព័ត៌មានថែមទៀតអំពី NAPLAN និង/ឬ ការផ្ទេរទៅអនឡាញ សូមចូលទៅ www.nap.edu.au